**PRESS STATEMENT**

# សេចក្ដីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី

ភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣

ថ្ងៃនេះ ខ្ញុំបានបិទបញ្ចប់បេសកកម្មស្វែងរកការពិតអំពីសិទ្ធិមនុស្សលើកទីប្រាំបួនរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជាហើយៗ អ្វីដែលខ្ញុំសូមលើកមកគូសបញ្ជាក់នោះគឺការរកឃើញដំបូងរបស់ខ្ញុំ និងការគិតអំពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ចាប់តាំងពីបេសកម្មលើកមុនរបស់ខ្ញុំ។ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយរបស់ខ្ញុំ នឹងបញ្ចូលក្នុងរបាយការណ៍របស់ខ្ញុំ ដែលខ្ញុំនឹងដាក់បង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅក្នុងខែកញ្ញាឆ្នាំនេះ។

ខ្ញុំត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩ ហើយខ្ញុំបានធ្វើរបាយការណ៍សំខាន់ៗធំៗចំនួនបួន ដែលមានការវិភាគយ៉ាងហ្មត់ចត់អំពីស្ថានភាពសិទ្ធិមនុស្ស និងបញ្ហាប្រឈមផ្សេងៗ ដែលប្រទេសកម្ពុជាកំពុងជួបប្រទះ ចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ របាយការណ៍ទាំងនេះត្រូវបានបញ្ជូនជារៀងរាល់ឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ដែលបានផ្ដោតលើកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត និងអំពីផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតទៅលើសិទ្ធិមនុស្ស។ របាយការណ៍នីមួយៗមានភ្ជាប់នូវកម្រងអនុសាសន៍ក្នុងន័យស្ថាបនា ដែលបានរៀបចំតាក់តែងឡើង ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការអនុវត្តរបៀបវារៈកំណែទម្រង់របស់ខ្លួន និងដំណើរការប្រជាធិបតេយ្យូបនីយកម្មនៅក្នុងប្រទេសកម្ពុជា។

មុនពេលខ្ញុំបំពេញបេសកកម្មមកកាន់ព្រះរាជាណាចក្រកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០១២ ខ្ញុំបានមានអារម្មណ៍ថា គឺជាពេលវេលាមួយសមស្រប សំរាប់ធ្វើការពិនិត្យមើលអំពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ទាំងឡាយដែលខ្ញុំបានដាក់ចេញក្នុងរបាយការណ៍មុនៗរបស់ខ្ញុំ និងដើម្បីកំណត់អំពីបញ្ហាប្រឈមដែលនៅសេសសល់។

ដូច្នេះ គោលបំណងនៃបេសកកម្មនេះ និងបេសកកម្មរបស់ខ្ញុំក្នុងខែធ្នូ ឆ្នាំ២០១២ គឺមានលក្ខណៈខុសប្លែកគ្នាតិចតួច ទៅនឹងបេសកកម្មលើកមុខៗរបស់ខ្ញុំ ត្រង់ថា ជាជាងការលើកឡើងអំពីបញ្ហាសិទ្ធិមនុស្សមួយថ្មី ឬការផ្ដោតលើគោលរឿងជាក់លាក់នៅក្នុងចំណុចប្រសព្វនេះ គឺបេសកកម្មលើកនេះផ្ដោតជាសំខាន់លើការពិនិត្យ

មើល អំពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ទាំងឡាយដែលខ្ញុំបានដាក់ចេញនៅក្នុងរបាយការណ៍មុនៗរបស់ខ្ញុំ ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចលើកនេះ ខ្ញុំមានលទ្ធភាពជួបជាមួយតួអង្គសំខាន់ៗពាក់ព័ន្ធជាច្រើន។ តួអង្គទាំងនោះ រួមមាន សមាជិកជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មការទទួលបន្ទុកកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ព័ត៌មាន និងសារព័ត៌មាននៃរដ្ឋសភា ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម ព្រហ្ម សិទ្ធត្រា រដ្ឋលេខាធិការក្រសួងយុត្តិធម៌។ ខ្ញុំមានក្តីសោមនស្សយ៉ាងខ្លាំងដោយមានការចូលរួម និងកិច្ចសន្ទនា ដែលខ្ញុំមានជាមួយឥស្សរជនទាំងនេះ។ កិច្ចសន្ទនាទាំងនេះបានប្រព្រឹត្តទៅដោយស្មោះត្រង់ ស្និទ្ធស្នាល និងក្នុងន័យស្ថាបនា។ ពួកគាត់មានព័ត៌មានដ៏សំខាន់ បានទទួលស្គាល់នូវចំណុចខ្វះខាតដែលនៅមាននៅឡើយ ហើយត្រៀមខ្លួនជានិច្ច ដើម្បីបំពេញការងារជាមួយខ្ញុំប្រកបដោយលក្ខណៈស្ថាបនា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលមាននៅសេសសល់ពាក់ព័ន្ធនឹងការការពារសិទ្ធិមនុស្សកាន់តែទូលំទូលាយ ប្រជាធិបតេយ្យកាន់តែរឹងមាំ និងនីតិរដ្ឋដ៏ពិតប្រាកដថែមទៀត។

មូលដ្ឋានគ្រឹះនៃការងាររបស់ខ្ញុំជាអ្នករាយការណ៍ពិសេស គឺឯករាជភាព ភាពមិនលំអៀង និងភាពសត្យា-នុម័ត។ ដើម្បីសំរេចគោលដៅនេះ នេះគឺជាការចាំបាច់បំផុតដែលក្នុងការអនុវត្តអាណត្តិការងាររបស់ខ្ញុំ ខ្ញុំមានឱកាសប្រាស័យទាក់ទងជាមួយមនុស្សគ្រប់ស្រទាប់ជាន់ថ្នាក់ក្នុងសង្គមកម្ពុជា។ អាស្រ័យហេតុនេះ ខ្ញុំសូមកត់សម្គាល់ដោយពេញចិត្តចំពោះកិច្ចប្រជុំរបស់ខ្ញុំ ជាមួយដៃគូសន្ទនានានារបស់រាជរដ្ឋាភិបាល ហើយខ្ញុំក៏មានឱកាសបានជួបប្រាស្រ័យជាមួយមនុស្សមួយក្រុមធំមកពីគ្រប់ជ្រុងនៃសង្គម នៅក្នុងអំឡុងពេលបំពេញបេសសកម្មរបស់ខ្ញុំ។ ខ្ញុំបានជួបប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងសង្គមកម្ពុជា រាប់ទាំងគណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល សហគមន៍មូលដ្ឋាន បុគ្គលឯកជន និងដៃគូអភិវឌ្ឍន៍របស់កម្ពុជា។

ទាក់ទងនឹងអនុសាសន៍នៅក្នុងរបាយការណ៍របស់ខ្ញុំ អំពីវិធី និងមធ្យោបាយនៃការពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់តុលាការ ខ្ញុំកត់សម្គាល់ឃើញថា ការវិវឌ្ឍន៍នៅក្នុងការអនុវត្តន៍អនុសាសន៍ទាំងអស់នេះ នៅមានភាពយឺតយ៉ាវខ្លាំងនៅឡើយ។ ទោះជាយ៉ាងណាក្តី ខ្ញុំត្រូវបានលើកទឹកចិត្តដោយការអះអាងដែលថា សេចក្តីព្រាងច្បាប់សំខាន់ៗទាំងបី ដែលជាផ្នែកមួយនៅក្នុងអនុសាសន៍ចម្បងរបស់ខ្ញុំ គឺជិតធ្វើបានរួចរាល់ហើយ ហើយនឹងត្រូវដាក់ឲ្យពិភាក្សានៅក្នុងសភានៅត្រឹមឆមាសទី១ នៃឆ្នាំ២០១៤។ រាជរដ្ឋាភិបាលហាក់ដូចជាបានផ្តួចផ្តើមនូវសកម្មភាពមួយចំនួន ដើម្បីធ្វើឲ្យប្រជាពលរដ្ឋទទួលបានសេវាកម្មតុលាការ

កាន់តែប្រសើរឡើងថែមទៀត ដែលជាការស្របទៅនឹងអនុសាសន៍របស់ខ្ញុំ ដែលរួមមាន ការពង្រឹងសមត្ថភាពរបស់សាលាឧទ្ធរណ៍ផងដែរ។

ទាក់ទងនឹងអនុសាសន៍របស់ខ្ញុំអំពីការកែទម្រង់សភា ខ្ញុំត្រូវបានលើកទឹកចិត្តដោយការឆ្លើយតបជាវិជ្ជមាន និងដោយឆន្ទៈមោះមុត ដើម្បីអនុវត្តអនុសាសន៍ទាំងនេះឲ្យបានច្រើនតាមតែអាចធ្វើបាន នៅក្នុងអាណត្តិសភាខាងមុខ។ ខ្ញុំបានទទួលព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងអនុវត្តតាមអនុសាសន៍របស់ខ្ញុំបានខ្លះ និងពីការលំបាកក្នុងការអនុវត្តអនុសាសន៍ខ្លះទៀត។ ទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត ខ្ញុំត្រូវបានលើកទឹកចិត្តដោយការឆ្លើយតបទៅនឹងអនុសាសន៍ម្តងមួយៗយ៉ាងពិស្តារ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ខ្ញុំដឹងពីការបារម្ភដែលបានលើកឡើងពីការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ប្រសិនជារកឃើញមែន ការបារម្ភទាំងនេះ គួរត្រូវបានលើកយកមកដោះស្រាយ។ ខ្ញុំទទួលបានព័ត៌មានថា វិធានការមួយចំនួនត្រូវបានចាត់ឡើង ដើម្បីសម្រួលដល់ដំណើរការបោះឆ្នោតឲ្យប្រព្រឹត្តទៅបានរលូន រួមទាំងការផ្សព្វផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលឥឡូវនេះ អាចរកឈ្មោះឃើញទាំងតាមប្រព័ន្ធអ៊ិនធឺណិត ទាំងតាមប្រព័ន្ធបិទផ្សាយនៅតាមមណ្ឌលបោះឆ្នោត ក្នុងរយៈពេលមួយខែមុនការបោះឆ្នោតមកដល់។ ខ្ញុំក៏ទទួលបានព័ត៌មានផងដែរថា ចៅក្រមចូលនិវត្តន៍ពីររូប ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីពង្រឹងឯករាជ្យភាពរបស់ គ.ជ.ប.។ ខ្ញុំសូមស្វាគមន៍ការវិវត្តន៍នេះ ដោយសារតែនេះជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍នានារបស់ខ្ញុំ ដែលថា សមាជិក គ.ជ.ប. គួរតែជ្រើសរើសឲ្យបានទូលាយជាងនេះ ដោយជ្រើសរើសចេញមកពីក្រុមចៅក្រមជាន់ខ្ពស់ដែលចូលនិវត្តន៍ មេធាវីជាន់ខ្ពស់នៃគណៈមេធាវី សាស្ត្រាចារ្យច្បាប់ រដ្ឋបាលសាធារណៈ និងវិទ្យាសាស្ត្រនយោបាយ នៃសកលវិទ្យាល័យ ជាដើម។ល។

ចំពោះអនុសាសន៍នៅក្នុងរបាយការណ៍របស់ខ្ញុំ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីគោលដៅដទៃទៀត ខ្ញុំដឹងថា របាយការណ៍នេះ ត្រូវបានដាក់ជូនរដ្ឋាភិបាល កាលពី ៨ ខែកន្លងទៅនេះ ហើយរដ្ឋាភិបាលអាចត្រូវការពេលវេលាថែមទៀត ដើម្បីពិចារណាលើអនុសាសន៍របស់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំកត់សំគាល់អំពីការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី របស់រដ្ឋាភិបាល ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រីផ្ទាល់។ ទន្ទឹមគ្នានឹងអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិនានាដែរ ខ្ញុំបានអំពាវនាវជាយូរមកហើយ សូមឲ្យមានការពន្លឿនកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ហើយបច្ចុប្បន្នកម្មវិធីនេះ បាននិងកំពុងអនុវត្ត ។ ខ្ញុំសូមលើកទឹកចិត្តរដ្ឋាភិបាលឲ្យបន្តនូវកម្មវិធីនេះ ដោយក្នុងពេលជាមួយគ្នានេះដែរ យកចិត្តទុកដាក់ខ្ពស់ចំពោះស្ថានភាពពិសេសនៃជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលរស់នៅលើដីមានទំនាស់។ នេះគឺជាឱកាសដ៏ល្អមួយ ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីនៃគ្រួសារប្រជាពលរដ្ឋជាច្រើន រាប់ទាំងគ្រួសារប្រជាពលរដ្ឋដែលមិនត្រូវបានរាប់បញ្ចូលនៅក្នុងកម្មវិធីនេះ និងក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីពីលើកមុនៗ ក៏ដូចជា គ្រួសារប្រជាពលរដ្ឋទាំងឡាយណា ដែលមានទំនាស់ដីធ្លីជាមួយបុគ្គលមានអំណាច និងក្រុមហ៊ុនឯកជន។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តបន្ថែមទៀតនូវក្របខ័ណ្ឌសិទ្ធិដីធ្លីដែលមានស្រាប់ និងការពង្រឹងស្ថាប័នគ្រប់គ្រងដីធ្លី គឺជាការចាំបាច់ដើម្បីឲ្យការវិវត្តន៍វិជ្ជមានដែលទទួលបាន មាននិរន្តរភាព។

កាលពីអំឡុងពេលបេសកកម្មលើកទី៧ របស់ខ្ញុំមកកាន់ប្រទេសកម្ពុជា ក្នុងខែឧសភា ឆ្នាំ២០១២ លោក
នាយករដ្ឋមន្ត្រី បានចេញបទបញ្ជាមួយ ដើម្បីផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី។ ជា
ថ្មីម្តងទៀត នេះគឺជាអ្វីដែលខ្ញុំ និងអ្នកពាក់ព័ន្ធដទៃទៀត បានស្នើឲ្យរដ្ឋាភិបាលផ្អាកការផ្តល់សម្បទានដីសេដ្ឋ
កិច្ច។ ខ្ញុំសូមកោតសរសើរចំពោះវិធានការនេះ និងរង់ចាំមើលអំពីការសន្យាធ្វើការពិនិត្យមើលឡើងវិញលើ
សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់។ បញ្ហាទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃផ្សេងទៀត ដែលរួមមានសហគមន៍បឹងកក់
បុរីកីឡា និងសហគមន៍នៅក្បែរព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដែលត្រូវតែមានការដោះស្រាយដោយ
គិតគូទៅដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីសេចក្តីសម្រេចដកហូតដីមកធ្វើការ
អភិវឌ្ឍន៍នេះ។ ខ្ញុំក៏កត់សំគាល់ផងដែរ អំពីលំនាំនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើសកម្មជនដីធ្លី។
ករណីពាក់ព័ន្ធនឹងអំពើហិង្សា និងការឃុំខ្លួនមួយចំនួន ត្រូវបានគេប្រាប់ឲ្យខ្ញុំដឹង ។

បេសកកម្មរបស់ខ្ញុំ នៅចំពេលដ៏សំខាន់ គឺក្នុងអំឡុងពេលដែលប្រទេសកម្ពុជា កំពុងត្រៀមរៀបចំការបោះ
ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយខ្ញុំទទួលបាននូវការបង្ហាញមួយចំនួនពាក់ព័ន្ធនឹងនីតិវិធីនៃការរៀបចំការ
បោះឆ្នោតមួយដែលត្រឹមត្រូវ និងយុត្តិធម៌។ ក្នុងករណីនេះ ខ្ញុំសូមស្នើម្តងទៀត ដល់គ្រប់គណបក្សនយោ-
បាយ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការធានាឲ្យមានការបោះឆ្នោតមួយដែលត្រឹមត្រូវ និង
យុត្តិធម៌ និងសន្តិភាព។ គ្រប់គណបក្សនយោបាយទាំងអស់ ត្រូវអនុវត្តតាមច្បាប់ បង្ហាញពីភាពចាស់ទុំក្នុង
ការជជែកដេញដោល ដោយមិនចូលរួមក្នុងល្បែងជេប្រមាថមើលងាយគ្នា។ គ្រប់គណបក្សនយោបាយទាំង
អស់ ត្រូវតែអាចចូលរួមបានក្នុងកំរិតស្មើគ្នា សម្រាប់ការប្រកួតប្រជែង។ ក្នុងករណីនេះ នៅក្នុងកិច្ចប្រជុំជា
ច្រើន ខ្ញុំបានបញ្ជាក់ម្តងហើយម្តងទៀត អំពីតម្រូវការនៃការទទួលបានភាពត្រឹមត្រូវ និងសមធម៌ ក្នុងការប្រើ
ប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ហើយនិងការហាមប្រាមជាដាច់ខាតការប្រើប្រាស់ធនធានរបស់រដ្ឋ បំរើឲ្យ
សកម្មភាពគណបក្សនយោបាយ។ ខ្ញុំត្រូវបានការធានាជាថ្មីទៀតផងដែរថា សេចក្តីណែនាំរបស់រដ្ឋាភិបាល
នឹងដាក់ចេញទៅដល់បុគ្គលិកទាំងអស់ ដែលបំរើការងារជា មន្ត្រីរាជការ យោធា នគរបាល មិនឲ្យចូលរួមក្នុង
សកម្មភាពនយោបាយ ក្នុងពេលបំពេញមុខងារភារកិច្ចរបស់ខ្លួនឡើយ។ បញ្ហានៃការបង្កើតឲ្យមានការរើស
អើងពូជសាសន៍ នៅក្នុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត ដោយគណបក្សនយោបាយខ្លះ ក៏ត្រូវបាន
គេប្រាប់ឲ្យខ្ញុំដឹងផងដែរ។ ខ្ញុំសូមស្នើឲ្យគ្រប់គណបក្សនយោបាយពាក់ព័ន្ធទាំងអស់ ចៀសវាងការកេង
ចំណេញ ដោយយកបញ្ហាពូជសាសន៍មកគាំទ្រ សំរាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្លួន ហើយធ្វើការ
សំដៅទៅកសាងភាពអត់អោន និងការបង្រួបបង្រួមសង្គមនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំនឹងបន្តតាមឃ្លាំមើល
ស្ថានភាពនៅក្នុងប្រទេសនេះ ហើយដើម្បីធ្វើកិច្ចការនេះ ខ្ញុំសូមស្នើសុំយ៉ាងទទូចដល់ពលរដ្ឋកម្ពុជាទាំងអស់
ឲ្យមានភាពអត់ធ្មត់ និងគោរពដល់សិទ្ធិរបស់អ្នកដទៃ នៅពេលអនុវត្តសិទ្ធិរបស់ខ្លួន។

សេរីភាពខាងការបញ្ចេញមតិ មានសារៈសំខាន់ជាសារវន្ត ទាំងចំពោះដំណើរការនៃការបោះឆ្នោត និងទាំង
ការអភិវឌ្ឍនៃដំណើរការប្រជាធិបតេយ្យរបស់ប្រទេស។ ការដោះលែងលោក ម៉ម សូណង់ដូ នាយកស្ថានីយ
វិទ្យុសំបុកឃ្មុំ គឺជាការវិវត្តន៍មួយដែលគួរឲ្យស្វាគមន៍។ ទោះជាយ៉ាងណាក៏ដោយ សេរីភាពខាងការបញ្ចេញ
មតិ ក៏នៅតែជាបញ្ហាកង្វល់សំរាប់ខ្ញុំ ដោយសារតែអ្នកទាំងឡាយដែលបំរើការនៅតាមប្រព័ន្ធផ្សព្វផ្សាយអាច

នឹងកំរិតការនិយាយស្តីរបស់ខ្លួន ព្រោះកន្លងមកមានចំណាត់ការយ៉ាងតឹងរឹង ទៅលើបុគ្គលមួយចំនួន ដែលបំរើការតាមប្រព័ន្ធផ្សព្វផ្សាយ និងទៅលើអ្នកការពារសិទ្ធិមនុស្ស។

ខ្ញុំនៅមានកង្វល់ផងដែរ អំពីវប្បធម៌និទណ្ឌភាពនៅកម្ពុជា និងបញ្ហីបទល្មើសជាច្រើន ដែលក្នុងនោះ មិនទាន់មានជនណាមួយ ត្រូវបាននាំខ្លួនមកផ្តន្ទាទោសតាមច្បាប់នៅឡើយ។ ខ្ញុំស្នើដល់រដ្ឋាភិបាល សូមពន្លឿនការស៊ើបអង្កេតរបស់ខ្លួន ទៅលើករណីទាំងនេះ ហើយនាំខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

សរុបសេចក្តីទៅ កម្ពុជាហាក់ដូចជា កំពុងធ្វើដំណើរនៅលើផ្លូវមួយឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ។ កម្ពុជាបានធ្វើដំណើរនៅលើផ្លូវដ៏វែងឆ្ងាយមួយនេះ ចាប់តាំងពីការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅក្នុងឆ្នាំ១៩៩១ និងការអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលបានបង្កើតឲ្យមានតំលៃផែនគ្រឹះបែបលិទ្ធិប្រជាធិបតេយ្យសេរីនៅក្នុងឆ្នាំ១៩៩៣។ ទោះបីជាយ៉ាងណាក៏ដោយ កម្ពុជានៅតែត្រូវធ្វើដំណើរលើកំណាត់ផ្លូវមួយនេះទៅមុខទៀត ក្នុងការលើកកំពស់ និងការការពារដល់សិទ្ធិមនុស្ស ពង្រឹងអភិបាលកិច្ចល្អ លើកស្ទួយដល់ឯករាជ្យភាព និងសមត្ថភាពរបស់ស្ថាប័នរដ្ឋទាំងឡាយដែលទទួលខុសត្រូវ ក្នុងការលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ ដូចដែលបានទទួលស្គាល់ដោយដៃគូសន្ទនាផ្សេងៗរបស់ខ្ញុំ មកពីខាងរដ្ឋាភិបាល ដែលខ្ញុំបានជួបនៅក្នុងអំឡុងពេលនៃដំណើរទស្សកិច្ចរបស់ខ្ញុំ។ ហេតុដូច្នេះ ខ្ញុំត្រៀមខ្លួនជាស្រេចក្នុងការជួយដល់រដ្ឋាភិបាលកម្ពុជា។ ខ្ញុំឃើញជាសញ្ញាមួយដែលរីកចំរើនទៅមុខ រដ្ឋាភិបាលបានទទួលស្គាល់រួចហើយនូវភាពចន្លោះប្រហោង នៅក្នុងជំនួបប្រជុំរបស់ខ្ញុំជាមួយពួកគាត់ ហើយបានបង្ហាញឆន្ទៈរបស់ខ្លួន ក្នុងការធ្វើការជាមួយខ្ញុំ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពសិទ្ធិមនុស្សសំរាប់ប្រជាពលរដ្ឋកម្ពុជា។

ខ្ញុំសូមយកឱកាសនេះ ដើម្បីថ្លែងអំណរគុណជាថ្មីម្តងទៀត ដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអញ្ជើញខ្ញុំមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា និងថ្លែងអំណរគុណផងដែរ ដែលបានចូលរួមក្នុងកិច្ចសន្ទនាប្រកបដោយអត្ថន័យ និងក្នុងន័យស្ថាបនា ជាមួយខ្ញុំនៅក្នុងអំឡុងពេលបំពេញបេសកកម្មនេះ។

គេបានប្រាប់ឲ្យខ្ញុំដឹងថា អាចមានភាពចន្លោះប្រហោងខ្លះ ក្នុងការធ្វើទំនាក់ទំនងគ្នាជាមួយរាជរដ្ឋាភិបាលនៅពេលថ្មីៗនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿថាដំណើរបេសកកម្មនេះបានបំពេញនូវចន្លោះប្រហោងនោះបាន និងបាននាំយើងត្រឡប់ទៅកាន់ផ្លូវមួយ ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការដូចធម្មតាឡើងវិញ។ មានការតវ៉ាពីរដែលបានរៀបចំធ្វើឡើងនៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ ដែលជាការតវ៉ាប្រឆាំងនឹងការងារសិទ្ធិមនុស្សរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែការតវ៉ាទាំងនេះ មិនបានធ្វើឲ្យខ្ញុំបាក់មុខ ឬធ្វើឲ្យខ្ញុំដាករចេញពីការងារដែលអង្គការសហប្រជាជាតិ ផ្តល់អាណត្តិឲ្យខ្ញុំបំពេញការងារនៅក្នុងប្រទេសកម្ពុជាឡើយ។ ប្រសិនជាយើងតាមដានមើលរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ការតវ៉ាទាំងពីរនេះទំនងជាត្រូវបានគេរៀបចំឡើង ហើយទំនងជាតំណាងឲ្យចំនួនមនុស្សភាគតិចបំផុតមួយនៅក្នុងប្រទេស ដែលពួកគេមានចេតនាធ្វើឲ្យខ្ញុំផ្លាស់ប្តូរគោលជំហរ។ ផ្ទុយទៅវិញ ខ្ញុំបែរជាទទួលបានការលើកទឹកចិត្តកាន់តែខ្លាំងឡើងថែមទៀត តាមរយៈសារគាំទ្រយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលខ្ញុំទទួលបានពីមនុស្សម្នាគ្រប់ស្រទាប់ជាន់ថ្នាក់ ដែលពួកគេគាំទ្រដល់ការងារដែលខ្ញុំបាននិងកំពុងធ្វើនៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យប្រទេសកម្ពុជា មាន

ភាពរីកចម្រើនខ្លាំងឡើងថែមទៀត និងដើម្បីសន្តិភាពជានិរន្ត ប្រជាធិបតេយ្យ និងវិបុលភាព ហើយខ្ញុំនឹងនៅតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំនេះ តទៅទៀត។

ខ្ញុំសូមអរគុណផងដែរ ដល់ដៃគូសន្ទនាឯទៀតរបស់ខ្ញុំ រាប់ទាំងសមាជិកសភា សង្គមស៊ីវិល និងក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា និងសហគមន៍អ្នកការទូត នៅរាជធានីភ្នំពេញ។ ជាសព្វដង ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ទាំងនៅទីក្រុងហ្សឺណែវ ទាំងនៅរាជធានីភ្នំពេញ បានផ្តល់ការគាំទ្រដល់ខ្ញុំផ្នែកភស្តុភារ និងបច្ចេកទេសចាំបាច់ដើម្បីឲ្យខ្ញុំអាចបំពេញការងាររបស់ខ្ញុំបាន
ហើយខ្ញុំសូមអរគុណដល់ពួកគេទាំងអស់នោះ។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គល លោកផ្ទាល់ ។ បច្ចុប្បន្នលោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស ហើយលោកគឺជាសមាជិកកណ:មេធាវីក្នុងអាជីព នៃគណ:មេធាវី the Middle Temple នៅទីក្រុងឡុង។ លោកគឺជាអនុប្រធានសង្គមអាស៊ានទទួលបន្ទុកនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្តីច្បាប់អន្តរជាតិរបស់អាស៊ាន ដោយការិយាល័យព័ត៌មាននៃសាកលវិទ្យាល័យ Cambridge ។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា ៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

សំរាប់សំណើរសុំព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចបញ្ជូនមកការិយាល័យឧត្តមស្នងការទទួល បន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ សូមទាក់ទងមកកញ្ញា ហ្ស៊ូអ៊ី ឡាធំបូ ទូរស័ព្ទលេខ Tel: + ៨៥៥ ០១២ ៧៩០ ១៧៨អ៊ីម៉េល zlatumbo@ohchr.org ឬ លោក **ទូច ហួន** ទូរស័ព្ទលេខ ០១២ ៤៧៦ ៩៩៣ អ៊ីម៉េល htouch@ohchr.org ។

សម្រាប់**ការសួរព័ត៌មាន**ទាក់ទងនឹងអ្នកជំនាញការឯករាជ្យ អ.ស.ប ផ្សេងៗទៀត សូមទំនាក់ទំនង៖
**សាប៉ៀរ ស៊ីលាយ៉ា** សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន ទូរស័ព្ទលេខ Tel: + ៤១ ២២ ៩១៧ ៩៣៨៣ អ៊ីម៉េល
*xcelaya@ohchr.org*

**សិទ្ធិមនុស្ស អ.ស.ប សូមស្វែងយល់ពីយើងតាមរយៈបណ្តាញសង្គម៖**

ហ្វេសប៊ុក ៖ **Facebook:** https://www.facebook.com/unitednationshumanrights
ធ្វីតធើរ ៖ **Twitter:** http://twitter.com/UNrightswire
ហ្គោហ្គឹល ៖ **Google+** gplus.to/unitednationshumanrights
យូធូប ៖ **YouTube:** http://www.youtube.com/UNOHCHR
**បរិយាយសាច់រឿង៖ Storify:** http://storify.com/UNrightswire